ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ២៨២សរ-១៥ អអក

ភ្នំពេញ, ថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ២០១៥

# សេចក្តីសម្រេច

## ស្តីពីការកែសម្រួលបន្ថែមលើសេចក្តីសម្រេច ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ៤៦១.សរ.១៥.អអក ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្តក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់ ចំពោះអ្នកផ្តល់សេវាអគ្គិសនីក្នុងការបង់អាករតម្លៃបន្ថែម លើចំណូលដែលបានមកពីការបង់ថ្លៃភ្ជាប់ចរន្ត និងថ្លៃសេវាបម្រើអតិថិជន របស់អ្នកស្នើសុំភ្ជាប់ចរន្តអគ្គិសនី។

## សម្រេច

**ប្រការ ១ .-**

កែសម្រួលខ្លឹមសារលើការកំណត់ «ថ្លៃភ្ជាប់ចរន្ត» ដែលបានចែងក្នុងប្រការ ១ និង «ថ្លៃសេវាបម្រើអតិថិជន» ចែងក្នុងប្រការ ៩ នៃសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ៤៦១.សរ.១៥.អអក ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការកំណត់ថ្លៃភ្ជាប់ចរន្ត ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី និងថ្លៃសេវាបម្រើអតិថិជន ដែលអ្នកផ្តល់សេវាអគ្គិសនីត្រូវអនុវត្តក្នុងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបន្ថែមខ្លឹមសារថា ៖ ថ្លៃកំណត់ទាំង២ ខាងលើនេះមានរួមបញ្ចូលនូវអាករតម្លៃបន្ថែម (VAT) ១០% ។



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៣ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**ប្រការ ២ .-**

សេចក្តីសម្រេចនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិស្តីពី «លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា» ។ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣ .-**

អ្នកផ្គត់ផ្គង់សេវាអគ្គិសនី មានភារៈកិច្ចផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះជាមួយអ្នកប្រើប្រាស់របស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ ឲ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

ចម្លងជូន ៖

- ក្រសួងរ៉ែ និងថាមពល
- សាលារាជធានីភ្នំពេញ-សាលាខេត្ត ពាក់ព័ន្ធ
- មន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត ពាក់ព័ន្ធ
- សាលាក្រុង-ខណ្ឌ-ស្រុក ពាក់ព័ន្ធ
- សាលាឃុំ-សង្កាត់ ពាក់ព័ន្ធ
  «ដើម្បីជូនជ្រាប»
- អ្នកផ្គត់ផ្គង់សេវាអគ្គិសនី ពាក់ព័ន្ធ
  «ដើម្បីផ្សព្វផ្សាយ និងអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



**អាជ្ញាធរអគ្គិសនីកម្ពុជា :** ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh